**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ**

លេខ: ៣៩៨ មស.នក

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០៩

**រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ**

**<u>សូមគោរពជូន</u>**

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**<u>កម្មវត្ថុ:</u>** ស្តីពីស្ថានភាព នៃការដំឡើងឋានន្តរស័ក្តិ ផ្ទេរ និងបញ្ចូលក្របខ័ណ្ឌមន្ត្រីរាជការនៅក្នុងដំណើរការរៀបចំ តែងតាំងគណ:អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**<u>យោង:</u>** -លិខិតលេខ ១២៨៣ សជណ ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៩ របស់ក្រសួងមហាផ្ទៃ ។

-ព្រះរាជក្រមលេខ សន/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរាជរដ្ឋភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

-ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិក:មន្ត្រីរាជកាស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី មេត្តា ជ្រាបថា: ដោយផ្អែកលើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដូចបានយោង ខាងលើត្រង់មាត្រា១២៦ ចែងថា **ក្នុងករណីចាំបាច់ អភិបាល អភិបាលរង អាចជ្រើសរើសពីក្នុងចំណោម មន្ត្រីរាជការទាំង២ភេទដែលស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល ក្រៅក្របខ័ណ្ឌក្រសួងមហាផ្ទៃបាន ប៉ុន្តែមន្ត្រី នោះត្រូវមានលក្ខណ:សម្បត្តិសមស្របតាមមាត្រា១៤២ មាត្រា១៤៣ មាត្រា ១៤៤ និងមាត្រា១៤៥ នៃច្បាប់នេះ** ។ ហើយដោយផ្អែកលើច្បាប់ស្តីពីសហលក្ខន្តិក:មន្ត្រីរាជកាស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ត្រង់មាត្រា៧ វាក្យខ័ណ្ឌទី១ចែងថា **អ្នករាជកាក្របខ័ណ្ឌ អាចដាក់ឱ្យទៅបំរើការ ឬបំពេញមុខងារក្រៅពីក្រមខ័ណ្ឌដើមរបស់ខ្លួនបាន ក្នុងករណីចាំបាច់និងមានការយល់ព្រមពីសាមីខ្លួន** ។ ដូចនេះទាក់ទងនឹងមន្ត្រីរាជការក្របខ័ណ្ឌក្រសួង ស្ថាប័ន ផ្សេងពីក្របខ័ណ្ឌក្រសួងមហាផ្ទៃ ហើយត្រូវបាន តែងតាំងក្នុងគណ:អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនោះ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណ: សូមជម្រាបជូនថា: **ក្នុងរយ:ពេលមកបំពេញភារកិច្ចថ្មីនេះចាំបាច់តម្រូវ ឱ្យសាមីខ្លួនត្រូវតែដាក់ពាក្យសុំ ស្ថិតនៅក្រៅក្របខ័ណ្ឌដើមនៅក្នុងក្រសួង ស្ថាប័នដើមរបស់ខ្លួន ហើយនៅ ពេលបញ្ចប់អាណត្តិត្រូវដាក់ ពាក្យសុំចូលបំរើការងារនៅក្រសួង ស្ថាប័នដើមរបស់ខ្លួនវិញ ។**

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមឧបនាយករដ្ឋមន្ត្រី មេត្តាជ្រាបដោយក្តីអនុគ្រោះ ។

សូមឯកឧត្តមឧបនាយករដ្ឋមន្ត្រី មេត្តាទទួលនូវការគោរព ដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

**ចម្លងជូន**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-គ្រប់ក្រសួង ស្ថាប័ន

វាយអត្ថបទដោយ: លោក ផាត់ ផ្លូវ៉ា

-គ្រប់សាលារាជធានី ខេត្ត
(ដើម្បីជូនជ្រាប)

-ឯកសារ-កាលប្បវត្តិ

**ពេជ្រ ប៊ុនធិន**

វាយអត្ថបទដោយៈ លោក ផាត់ ឆ្នាំ